ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ៣៤៣ ប្រក.កសក

# ប្រកាស
# ស្តីពី
# នីតិវិធី និងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកត/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឱ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការ និងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាន និងឯកសារកសិកម្មចំណុះក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផលឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្មឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ



អាសយដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
Nº 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ: (០២៣) ៧២៦ ១២៨ / ៧២៦ ១២៩ ទូរសារលេខ: (៨៥៥) ២៣-២១៧ ៣២០
Phone: (023) 726 128 / 726 129, Fax: (855) 23-217 320

- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយក-ដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញអនុក្រឹត្យលេខ៨១ អនក្រ.កប ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩ ស្តីពីការកែសម្រួលមាត្រា២ មាត្រា២៥ មាត្រា២៦ និងមាត្រា៣៥ នៃអនុក្រឹត្យលេខ១៨៨ អនក្រ.កប ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ និងមាត្រា២៧ថ្មី នៃអនុក្រឹត្យលេខ១១៨ អនក្រ.កប ចុះថ្ងៃទី២៦ ខែកក្កដា ឆ្នាំ២០១៧
- បានឃើញប្រកាសអន្តរក្រសួងលេខ១៨២០ កយ.កសក/១៩ ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ដល់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងកំណត់ពីនីតិវិធី និងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីលើកកម្ពស់ប្រសិទ្ធភាពនៃការអនុវត្តច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ តាមរយៈការបង់ប្រាក់ពិន័យអន្តរការណ៍។

**ប្រការ២ .-**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះការពិន័យអន្តរការណ៍លើបទល្មើស ដូចមានចែងក្នុងមាត្រា ១១០ មាត្រា១១១ មាត្រា១១២ និងមាត្រា១១៣ នៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។

## ជំពូកទី២
## សមត្ថកិច្ចពិន័យអន្តរការណ៍

**ប្រការ៣ .-**

ការពិន័យអន្តរការណ៍លើបទល្មើស ដែលមានចែងក្នុងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វជាសមត្ថកិច្ចរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល។

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ មានសមត្ថកិច្ចពិន័យអន្តរការណ៍លើបទល្មើសដែលមានចែងក្នុងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា។

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត មានសមត្ថកិច្ចពិន័យអន្តរការណ៍លើបទល្មើសដែលមានចែងក្នុងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វនៅក្នុងដែនសមត្ថកិច្ចសាមី។

**ប្រការ៤ .-**

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ មានសមត្ថកិច្ចសម្រេចពិន័យអន្តរការណ៍លើគ្រប់បទល្មើសដែលមានចែងក្នុងមាត្រា១១០ មាត្រា១១១ មាត្រា១១២ និងមាត្រា១១៣ នៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។

**ប្រការ៥ .-**

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត មានសមត្ថកិច្ចសម្រេចពិន័យអន្តរការណ៍លើបទល្មើស ដែលមានចែងក្នុងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដូចខាងក្រោម៖

**ក- ចំណុចទី១ ទី២ ទី៣ ទី៤ និងទី៥ នៃមាត្រា១១០**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ១០០ ០០០ (មួយសែន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

១- មិនធ្វើអនាម័យសត្តឃាតដ្ឋាន ទីកន្លែងកែច្នៃបឋមផលិតផលសត្វ ទីកន្លែងអាជីវកម្មសត្វ ទីកន្លែងតាំងលក់សាច់ មន្ទីរព្យាបាលសត្វ ទីកន្លែងព្យាបាលសត្វ ទីកន្លែងចិញ្ចឹមសត្វ និងបង្កាត់ពូជសត្វ ទីកន្លែងផលិត លាយផ្សំ ផ្គត់ផ្គង់ និងលក់ចែកចាយបសុឱសថ ទីកន្លែងផលិត លាយផ្សំ ផ្គត់ផ្គង់ និងលក់ចែកចាយចំណីសត្វ ទីកន្លែងប្រមូលផ្តុំរក្សាសត្វ និងស្ថានីយចត្តាឡីស័កសត្វ និងផលិតផលសត្វ។

២- មិនអនុវត្តតាមលក្ខខណ្ឌដែលភ្ជាប់កាតព្វកិច្ចក្នុងការកាន់លិខិតអនុញ្ញាត ឬវិញ្ញាបនបត្រទាំងឡាយដែលពាក់ព័ន្ធនឹងសត្វ ផលិតផលសត្វ បសុឱសថ និងចំណីសត្វ ដូចមានចែងក្នុងចំណុច១ ដល់ចំណុច៥ កថាខណ្ឌទី១ មាត្រា៨៨ នៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។

៣- មិនអនុវត្តតាមបទប្បញ្ញត្តិហាមឃាត់នៅក្នុងតំបន់ឆ្លងជំងឺសត្វ និងតំបន់ត្រួតពិនិត្យជំងឺសត្វ ក្នុងការធ្វើចរាចរណ៍សត្វ និងផលិតផលសត្វដែលធ្វើឲ្យរាលដាលជំងឺឆ្លងសត្វ។

៤- មិនចូលរួមអនុវត្តវិធានការបសុព្យាបាលទប់ស្កាត់ជំងឺឆ្លងសត្វ នៅក្នុងតំបន់ឆ្លងជំងឺសត្វ និងតំបន់ទប់ស្កាត់ជំងឺសត្វ តាមសេចក្តីណែនាំរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល។

៥- មិនចូលរួមអនុវត្តការសម្អាត ការកម្ចាត់មេរោគចំពោះអគារ ឧបករណ៍ សម្ភារបរិក្ខារ មធ្យោបាយដឹកជញ្ជូននៅក្នុងតំបន់ឆ្លងជំងឺសត្វ តាមសេចក្តីណែនាំរបស់អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល។

**ខ- ចំណុចទី១ ទី២ និងទី៨ នៃមាត្រា១១១**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៤ ០០០ ០០០ (បួនលាន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

១- លក់ដុំ លក់រាយបសុឱសថ ឬចំណីសត្វដោយគ្មានលិខិតអនុញ្ញាតស្របតាមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។

២- មិនអនុវត្តតាមកាតព្វកិច្ចអ្នកកាន់លិខិតអនុញ្ញាតដូចមានចែងក្នុងចំណុច៦ កថាខណ្ឌទី១ មាត្រា៨៨ នៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។

៨- ធ្លាប់បានទទួលទណ្ឌកម្មដូចមានចែងក្នុងមាត្រា១០៩ នៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។

**គ- ចំណុចទី១ ទី៤ ទី៥ ទី៦ ទី៩ និងទី១០ នៃមាត្រា១១២**

ត្រូវពិន័យអន្តរការណ៍ជាប្រាក់ ៧ ០០០ ០០០ (ប្រាំពីរលាន) រៀល ចំពោះបុគ្គលណាដែលប្រព្រឹត្តអំពើណាមួយដូចខាងក្រោម៖

១- បោះបង់ចោល លែងចោល ពិឃាតយកសាច់ធ្វើជាអាហារ ដើម្បីយកផលិតផលធ្វើជាអាហារ លក់ដូរ កែច្នៃ ឬចែកចាយដល់សាធារណជន ឬធ្វើចរាចរណ៍សត្វ ឬផលិតផលសត្វដែលមានជំងឺ ឬសង្ស័យថាឆ្លងជំងឺវិញ្ញត្តិ។

៤- ធ្វើសន្និធិ ឬលក់ចែកចាយសាច់សត្វ ឬផលិតផលសត្វដោយគ្មានត្រា ឬស្លាកបសុព្យាបាលសម្គាល់។

៥- មិនអនុវត្តតាមបទដ្ឋានបច្ចេកទេសសម្រាប់សំបកវេចខ្ចប់ និងស្លាកសញ្ញាព័ត៌មានជាភាសាខ្មែរសម្រាប់បសុឱសថ ឬចំណីសត្វ។

៦- មិនអនុវត្តតាមបទដ្ឋានបច្ចេកទេសបសុព្យាបាលដូចមានចែងក្នុងមាត្រា៥៧ នៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។

៩- លក់ដុំ លក់រាយបសុឱសថ ឬចំណីសត្វខុសការកំណត់ក្នុងលិខិតអនុញ្ញាតនាំចូល។

១០- ចិញ្ចឹមសត្វ ឬបង្កាត់ពូជសត្វជាលក្ខណៈពាណិជ្ជកម្មដោយគ្មានលិខិតអនុញ្ញាត និងមិនបានចុះបញ្ជីកសិដ្ឋានស្របតាមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។

**ប្រការ៦ .-**

ក្នុងករណី មានការពិន័យអន្តរការណ៍លើបទល្មើសផ្សេងក្រៅពីចំណុច ក ចំណុច ខ និងចំណុច គ ខាងលើ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី ត្រូវបញ្ជូនសំណុំរឿង និងភ្ជាប់មកជាមួយនូវកំណត់ហេតុត្រួតពិនិត្យ សំណុំលិខិតដោះស្រាយបទល្មើស និងលិខិតសារភាពកំហុសនិងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍របស់ជនល្មើស មកអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីធ្វើការសម្រេចលើការបង់ប្រាក់ពិន័យអន្តរការណ៍ស្របតាមនីតិវិធី និងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងប្រកាសនេះ។

## ជំពូកទី៣
## នីតិវិធី និងសិទ្ធិពិន័យអន្តរការណ៍

**ប្រការ៧ .-**

ក្នុងពេលប្រតិបត្តិការអនុវត្តច្បាប់ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌ ត្រូវមានលិខិតបញ្ជាបេសកកម្ម ត្រូវស្លៀកពាក់ឯកសណ្ឋាន សញ្ញាសម្គាល់ និងឋានន្តរសក្តិ ត្រូវបំពេញភារកិច្ច និងមានសិទ្ធិចាត់វិធានការលើបទល្មើសស្របតាមច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងប្រកាសនេះ។

**ប្រការ៨ .-**

នៅពេលអនុវត្តពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ នៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវធ្វើរបាយការណ៍ដោយភ្ជាប់កំណត់ហេតុត្រួតពិនិត្យ សំណុំលិខិតដោះស្រាយបទល្មើស លិខិតសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍របស់ជនល្មើសមកអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីធ្វើការសម្រេចស្របតាមនីតិវិធី និងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងប្រកាសនេះ។

ក្នុងករណីពិន័យអន្តរការណ៍លើបទល្មើសស្ថិតក្នុងដែនរាជធានី ខេត្ត មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ នៃមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី ត្រូវធ្វើរបាយការណ៍ដោយភ្ជាប់កំណត់ហេតុត្រួតពិនិត្យ សំណុំលិខិតដោះស្រាយបទល្មើស លិខិតសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍របស់ជនល្មើស មកមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី ដើម្បីធ្វើការសម្រេចស្របតាមនីតិវិធី និងបទប្បញ្ញត្តិនៃច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ និងប្រកាសនេះ។

**ប្រការ៩ .-**

ការពិន័យអន្តរការណ៍អាចអនុវត្តបានតែក្នុងករណីជនល្មើសយល់ព្រមសារភាពកំហុសជាលាយលក្ខណ៍អក្សរ និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ តាមការសម្រេចរបស់អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត។

ក្នុងករណីជនល្មើសមិនព្រមសារភាពកំហុសនិងបង់ប្រាក់ពិន័យអន្តរការណ៍ មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌មានសមត្ថកិច្ច ត្រូវចងក្រងសំណុំរឿងនៃបទល្មើស ដើម្បីបញ្ជូនទៅតុលាការតាមនីតិវិធី។

**ប្រការ១០ .-**

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវចេញសេចក្តីសម្រេចពិន័យអន្តរការណ៍ក្នុងរយៈពេល១០(ដប់) ថ្ងៃយ៉ាងយូរ គិតចាប់ពីថ្ងៃទទួលលិខិតសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍របស់ជនល្មើស។

ជនល្មើសត្រូវបង់ប្រាក់ពិន័យអន្តរការណ៍នៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី នូវចំនួនទឹកប្រាក់ដូចបានកំណត់ក្នុងសេចក្តីសម្រេចពិន័យអន្តរការណ៍ នៅក្នុងរយៈពេលមិនលើសពី ១០(ដប់)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច។

គំរូទម្រង់លិខិតសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ និងសេចក្តីសម្រេចស្តីពីការពិន័យអន្តរការណ៍លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

**ប្រការ១១ .-**

នៅក្រោយពេលបង់ប្រាក់ពិន័យអន្តរការណ៍គ្រប់ចំនួនរួច សាមីជនត្រូវបានរួចផុតពីការចោទប្រកាន់ទៅតុលាការ រីឯវត្ថុតាងនៃបទល្មើសត្រូវប្រគល់ជូនសាមីជនវិញ លើកលែងតែវត្ថុតាងជាសត្វ ផលិតផលសត្វ ចំណីសត្វ បសុឱសថ ឬសារធាតុទាំងឡាយណាអាចបង្កជាជំងឺ ឬគ្រោះថ្នាក់ដល់ជីវិត សុខភាពមនុស្ស សត្វ និងបរិស្ថាន ដែលហាមឃាត់ដោយច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ។

ក្នុងករណីដែលវត្ថុតាងមិនអាចរក្សាទុកបានយូរដែលបណ្តាលមកពីភាពស្អុយរលួយ ធ្វើឲ្យបាត់បង់បរិមាណ គុណភាព ហួសពេលកំណត់ប្រើប្រាស់ ពុកផុយ ចម្លងមេរោគ ឬមិនស្គាល់អត្តសញ្ញាណម្ចាស់ ឬអ្នកកាន់កាប់វត្ថុតាងនៃបទល្មើស មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ ត្រូវស្នើសុំការសម្រេចពីព្រះរាជអាជ្ញា ដើម្បីធ្វើការបំផ្លាញចោល ឬលក់វត្ថុតាងទាំងនោះតាមនីតិវិធី។

**ប្រការ១២ .-**

ការចំណាយលើវត្ថុវិភាគ សេវាកម្មវិភាគ ការលើកដាក់ ការដឹកជញ្ជូន ការថែរក្សា និងការបំផ្លាញចោលវត្ថុតាងនៅក្នុងដំណើរការអនុវត្តច្បាប់ ជាបន្ទុករបស់ម្ចាស់ ឬអ្នកកាន់កាប់វត្ថុតាងនៃបទល្មើស។

ក្នុងករណីមិនស្គាល់អត្តសញ្ញាណម្ចាស់ ឬអ្នកកាន់កាប់វត្ថុតាងនៃបទល្មើស រាល់ការចំណាយជាបន្ទុករបស់រដ្ឋ។ អង្គភាពទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ត្រូវស្នើសុំព្រះរាជអាជ្ញាមានសមត្ថកិច្ចដើម្បីរឹបអូសវត្ថុតាងនៃបទល្មើសជាសម្បត្តិរដ្ឋ ឬបំផ្លាញចោលតាមវិធានការបសុព្យាបាល។

**ប្រការ១៣ .-**

អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវបង់ប្រាក់ចំណូលដែលបានមកពីការពិន័យអន្តរការណ៍ ចូលថវិកាជាតិតាមរយៈរតនាគារជាតិ ឬ រតនាគាររាជធានី ខេត្តសាមី ស្របតាមនីតិវិធី។

មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវធ្វើរបាយការណ៍ជាប្រចាំជូនអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ អំពីរាល់ករណីពិន័យអន្តរការណ៍ដែលបានអនុវត្ត។

**ប្រការ១៤ .-**

ជនល្មើសដែលធ្លាប់ទទួលរងនូវពិន័យអន្តរការណ៍ម្តងហើយ ហើយនៅតែបន្តប្រព្រឹត្តអំពើល្មើសទៀត ត្រូវពិន័យអន្តរការណ៍ជាប្រាក់ទ្វេដង។ ករណីនៅមានកំហុសលើបទល្មើសដដែលទៀត អង្គភាពជំនាញទទួលបន្ទុកផលិតកម្ម និងបសុព្យាបាល ត្រូវដកហូតវិញ្ញាបនបត្រ ឬលិខិតអនុញ្ញាតគ្រប់ប្រភេទ និងចងក្រងសំណុំរឿងបញ្ជូនទៅតុលាការតាមនីតិវិធី។

ករណីខកខានក្នុងការបង់ប្រាក់ពិន័យអន្តរការណ៍ផុតរយៈពេល ១០(ដប់)ថ្ងៃ គិតចាប់ពីថ្ងៃចេញសេចក្តីសម្រេច អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ឬមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្តសាមី ត្រូវចងក្រងសំណុំរឿងទៅតុលាការតាមនីតិវិធី។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**ប្រការ១៥ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១៦ .-**

អគ្គលេខាធិការ អគ្គាធិការ អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធាននាយកដ្ឋាននីតិកម្មកសិកម្ម ប្រធានគ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានី ខេត្ត ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៨ រោច ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១០ ខែកញ្ញា ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល** :
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួង ស្ថាប័នពាក់ព័ន្ធ
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានី ខេត្ត
- ដូចប្រការ១៦
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.................................ភេទ..........អាយុ.......... ឆ្នាំ សញ្ជាតិ...........
អាសយដ្ឋានបច្ចុប្បន្ន៖ .......................................................................................................
.......................................................................................................................
មុខរបរ៖.........................................................................................................
☐ កាន់អត្តសញ្ញាណប័ណ្ណលេខ...................................ផុតកំណត់៖.......................................
☐ លិខិតឆ្លងដែនលេខ...............................................ផុតកំណត់៖.......................................

### សូមគោរពជូន
### ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

**កម្មវត្ថុ** ៖ សេចក្ដីសារភាពកំហុស និងស្នើសុំបង់ប្រាក់ពិន័យអន្តរការណ៍។
**យោង** ៖ កំណត់ហេតុត្រួតពិនិត្យ ចុះថ្ងៃទី..........ខែ......................ឆ្នាំ២០.........របស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌។

សេចក្ដីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំ សូមគោរពជម្រាបជូន **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី......... ខែ............ ឆ្នាំ២០........វេលាម៉ោង .............................ខ្ញុំបាទ/នាងខ្ញុំបានប្រព្រឹត្តល្មើសនឹងច្បាប់ស្ដីពីសុខភាពសត្វ និងផលិតកម្មសត្វ ដូចបានចុះក្នុងកំណត់ហេតុត្រួតពិនិត្យរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌មានសមត្ថកិច្ចដូចខាងក្រោម៖

.......................................................................................................................
.......................................................................................................................
.......................................................................................................................
.......................................................................................................................
.......................................................................................................................
.......................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

..........................................................................................................................................

ខ្ញុំបាទ/នាងខ្ញុំសូមសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ចំនួន........................

..........................................................................................................................................

(សរសេរជាអក្សរ៖..........................................................................................................)
ស្របតាមសេចក្តីសម្រេចពិន័យអន្តរការណ៍លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីរំលត់បណ្តឹងអាជ្ញា និងរួចផុតពីការចោទប្រកាន់ទៅតុលាការ។

ខ្ញុំបាទ/នាងខ្ញុំសូមសន្យាថានឹងឈប់ប្រព្រឹត្តល្មើសច្បាប់ដូចខាងលើចាប់ពីពេលនេះតទៅ ខ្ញុំសូមផ្តិតស្នាមម្រាមដៃទុកជាភស្តុតាងចំពោះមុខច្បាប់។

អាស្រ័យហេតុនេះ សូម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ** មេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥

.........................ថ្ងៃទី............ខែ.................ឆ្នាំ ២០........

**ស្នាមម្រាមដៃជនសារភាពកំហុស**

បានឃើញសាមីជនផ្តិតម្រាមដៃនៅចំពោះមុខ និងសូម
គោរពជូនឯកឧត្តមប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួល
បន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ
និងផលិតកម្មសត្វ ពិនិត្យ និងសម្រេច។
**មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

សំណុំរឿងលេខ សរ.អសផស

## សេចក្តីសម្រេច
## ស្តីពី
## ការពិន័យអន្តរការណ៍លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

## ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា
## អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៨២០/១៩ កយ.កសក.ប្រក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ដល់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញប្រកាសលេខ................................ប្រក.កសក ចុះថ្ងៃទី...........ខែ................ឆ្នាំ២០.......ស្តីពីនីតិវិធី និងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញសេចក្តីសម្រេចលេខ ១៣៦ សសរ.កសក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ស្តីពីការតែងតាំងមន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញកំណត់ហេតុត្រួតពិនិត្យ ចុះថ្ងៃទី..............ខែ................ឆ្នាំ២០......... របស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌មានសមត្ថកិច្ច
- យោងតាមលិខិតសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍របស់ជនល្មើស ចុះថ្ងៃទី.........ខែ....................... ឆ្នាំ២០......

## សម្រេច

**ប្រការ១ .-**

ធ្វើការពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖...........................................................................

(សរសេរជាអក្សរ៖.............................................................................................................)

ចំពោះឈ្មោះ.................................................. ភេទ............. អាយុ............ឆ្នាំ សញ្ជាតិ.....................

អាសយដ្ឋានបច្ចុប្បន្ន៖.............................................................................................................

.............................................................................................................................................

ដែលបានប្រព្រឹត្តល្មើសផ្ទុយនឹងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដូចខាងក្រោម៖

មាត្រា............ ចំណុចទី..........ពីបទ៖...........................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.......................................................................................................................................................

.....................................................................................................................................................។

**ប្រការ២ .–**

ជនល្មើសត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល១០(ដប់)ថ្ងៃគិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះ នៅអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វដើម្បីបញ្ចប់សំណុំរឿងនៃបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ។

**ប្រការ៣ .–**

ក្នុងករណី សាមីជនមិនបានបង់ប្រាក់ពិន័យអន្តរការណ៍តាមចំនួន ដូចបានកំណត់នៅក្នុងសេចក្តីសម្រេចនេះ មុនថ្ងៃទី......... ខែ............... ឆ្នាំ.............. ទេ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វនឹងអនុវត្តវិធានការច្បាប់បន្តនិងរៀបចំចងក្រងសំណុំរឿងនៃបទល្មើស ដើម្បីបញ្ជូនទៅតុលាការតាមនីតិវិធី។

**ប្រការ៤ .–**

សាមីជនដែលសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥

........................ថ្ងៃទី..........ខែ................ឆ្នាំ ២០.....

**ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជា**
**អគ្គនាយកនៃអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ**

**ចម្លងជូន៖**

- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៤
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ

## ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.............................ភេទ.........អាយុ......... ឆ្នាំ សញ្ជាតិ......................
អាសយដ្ឋានបច្ចុប្បន្ន៖ ..........................................................................................................
..........................................................................................................................................
មុខរបរ៖.............................................................................................................................
☐ កាន់អត្តសញ្ញាណប័ណ្ណលេខ................................ផុតកំណត់៖............................................
☐ លិខិតឆ្លងដែនលេខ...........................................ផុតកំណត់៖............................................

**សូមគោរពជូន**

**លោកប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ..........................**

**កម្មវត្ថុ** ៖ សេចក្តីសារភាពកំហុស និងស្នើសុំបង់ប្រាក់ពិន័យអន្តរការណ៍។
**យោង** ៖ កំណត់ហេតុត្រួតពិនិត្យ ចុះថ្ងៃទី.............ខែ.................ឆ្នាំ២០.........របស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំបាទ/នាងខ្ញុំសូមគោរពជម្រាបជូន **លោកប្រធានមន្ទីរ** មេត្តាជ្រាបថា៖ កាលពីថ្ងៃទី............. ខែ................ ឆ្នាំ២០........... វេលាម៉ោង ......................ខ្ញុំបាទ/នាងខ្ញុំបានប្រព្រឹត្តល្មើសនឹងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដូចបានចុះក្នុងកំណត់ហេតុត្រួតពិនិត្យរបស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌មានសមត្ថកិច្ចដូចខាងក្រោម៖

..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................
..........................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

..........................................................................................................................................................

ខ្ញុំបាទ/នាងខ្ញុំសូមសារភាពកំហុសនិងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ចំនួន.......................
..........................................................................................................................................................
(សរសេរជាអក្សរ៖..........................................................................................................)
ស្របតាមសេចក្តីសម្រេចពិន័យអន្តរការណ៍លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីរំលត់បណ្តឹងអាជ្ញា និងរួចផុតពីការចោទប្រកាន់ទៅតុលាការ។

ខ្ញុំបាទ/នាងខ្ញុំ សូមសន្យាថានឹងឈប់ប្រព្រឹត្តល្មើសច្បាប់ដូចខាងលើចាប់ពីពេលនេះតទៅខ្ញុំសូមផ្តិតស្នាមម្រាមដៃទុកជាភស្តុតាងចំពោះមុខច្បាប់។

អាស្រ័យហេតុនេះ សូម **លោកប្រធានមន្ទីរ** មេត្តាពិនិត្យ និងសម្រេចដោយអនុគ្រោះ។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥
.......................ថ្ងៃទី..........ខែ................ឆ្នាំ ២០.....
**ស្នាមម្រាមដៃជនសារភាពកំហុស**

បានឃើញសាមីជនផ្តិតម្រាមដៃនៅចំពោះមុខ
និងសូមគោរពជូនលោកប្រធាន
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ.....................
ដើម្បីពិនិត្យ និងសម្រេច។
**មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ...........

សំណុំរឿងលេខ                    សរ.មកសក.ផប

# សេចក្តីសម្រេច
## ស្តីពី
## ការពិន័យអន្តរការណ៍លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ

### ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ.....

- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១៦/០០៣ ចុះថ្ងៃទី២៨ ខែមករា ឆ្នាំ២០១៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញប្រកាសអន្តរក្រសួងលេខ ១៨២០/១៩ កយ.កសក.ប្រក ចុះថ្ងៃទី១៦ ខែកញ្ញា ឆ្នាំ២០១៩ ស្តីពីការផ្តល់នីតិសម្បទាជានគរបាលយុត្តិធម៌ដល់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញប្រកាសលេខ...........................ប្រក.កសក ចុះថ្ងៃទី............ខែ.................ឆ្នាំ២០.............ស្តីពីនីតិវិធី និងសិទ្ធិពិន័យអន្តរការណ៍លើបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញសេចក្តីសម្រេចលេខ១៣៦ សសរ.កសក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩ ស្តីពីការតែងតាំងមន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វ
- បានឃើញកំណត់ហេតុត្រួតពិនិត្យ ចុះថ្ងៃទី.......... ខែ............ ឆ្នាំ២០........ របស់មន្ត្រីអធិការកិច្ចសុខភាពសត្វ និងផលិតកម្មសត្វដែលមាននីតិសម្បទាជានគរបាលយុត្តិធម៌មានសមត្ថកិច្ច
- យោងតាមលិខិតសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍របស់ជនល្មើស ចុះថ្ងៃទី.........ខែ......................... ឆ្នាំ២០.........

## សម្រេច

**ប្រការ១ .-**

ធ្វើការពិន័យអន្តរការណ៍ជាប្រាក់ចំនួន៖.......................................................................
(សរសេរជាអក្សរ៖.......................................................................................................)
ចំពោះឈ្មោះ.............................................. ភេទ............. អាយុ.......... ឆ្នាំ សញ្ជាតិ...............
អាសយដ្ឋានបច្ចុប្បន្ន៖..............................................................................................................
.......................................................................................................................................
ដែលបានប្រព្រឹត្តល្មើសផ្ទុយនឹងច្បាប់ស្តីពីសុខភាពសត្វ និងផលិតកម្មសត្វ ដូចខាងក្រោម៖
មាត្រា............. ចំណុចទី............ ពីបទ៖.............................................................................

..........................................................................................................................................................................................

..........................................................................................................................................................................................

..........................................................................................................................................................................................

..........................................................................................................................................................................................

..........................................................................................................................................................................................

..........................................................................................................................................................................................

..........................................................................................................................................................................................។

**ប្រការ២ .–**

ជនល្មើសត្រូវបង់ប្រាក់ពិន័យអន្តរការណ៍ក្នុងរយៈពេល១០(ដប់)ថ្ងៃគិតចាប់ពីថ្ងៃចេញសេចក្តីសម្រេចនេះនៅនៅមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ.................................. ដើម្បីបញ្ចប់សំណុំរឿងនៃបទល្មើសសុខភាពសត្វ និងផលិតកម្មសត្វ។

**ប្រការ៣ .–**

ក្នុងករណីសាមីជនមិនបានបង់ប្រាក់ពិន័យអន្តរការណ៍តាមចំនួន ដូចបានកំណត់នៅក្នុងសេចក្តីសម្រេចនេះ មុនថ្ងៃទី................. ខែ............... ឆ្នាំ.................... ទេ មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ............................................ នឹងអនុវត្តវិធានការច្បាប់បន្តនិងរៀបចំចងក្រងសំណុំរឿងនៃបទល្មើសដើម្បីបញ្ជូនទៅតុលាការតាមនីតិវិធី។

**ប្រការ៤ .–**

សាមីជនដែលសារភាពកំហុស និងយល់ព្រមបង់ប្រាក់ពិន័យអន្តរការណ៍ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ខែ ឆ្នាំ ព.ស.២៥

......................... ថ្ងៃទី........... ខែ................ ឆ្នាំ ២០.......

**ប្រធាន**

**មន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**.........................

**ចម្លងជូនៈ**

- អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ
  "ដើម្បីជូនជ្រាប"
- ដូចប្រការ៤
  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ